# សន្តិសុខនៅផ្ទះ និង សុវត្ថិភាពនៃភ្លើងឆេះ

Fact Sheet 22 – Community Risk Management. Revised 28/09/2004 - Khmer

- **NSW FIRE BRIGADES**
- **ACT FIRE BRIGADE**
- **NSW RURAL FIRE SERVICE**
- **ACT RURAL FIRE SERVICE**

## ហេតុការណ៍

មួយឆ្នាំៗនៅរដ្ឋ (NSW) ម្ចាស់ផ្ទះខ្លះបានជួបប្រទះនូវការលំបាកក្នុងការគេចចេញពីភ្លើងឆេះនៅក្នុងផ្ទះរបស់ខ្លួនដោយសារវិធានការនានាហើយនិងប្រហែលអាចស្លាប់ទៀតផងដោយហេតុពីការបង្កើនរបង្អង់ ។ យើងសូមផ្តល់ឱវាទឲ្យមានការថ្លឹងថ្លែងរវាងសន្តិសុខនៅផ្ទះ និងសុវត្ថិភាពនៅផ្ទះ ។ វាសំខាន់ណាស់ចំពោះការចាក់សោមិនឲ្យអ្នកឈ្លានពានចូលបាន, ប៉ុន្តែក្នុងករណីភ្លើងឆេះវិញ, វាក៏សំខាន់ណាស់ដែរដែលមិនចាក់សោរូបលោកអ្នក ឬគ្រួសារលោកអ្នកជាប់នៅកងផះ ។

**កំរិតសន្តិសុខណាមួយក៏ដោយដែលលោកអ្នកជ្រើសរើសសំរាប់ផ្ទះលោកអ្នកនោះ យើងសូមផ្តល់ឱវាទថា លោកអ្នកត្រូវមានការប្រយ័ត្នប្រយែងថែមទៀតពេលដែលលោកអ្នកប៉ាន់មើលកំរិតគ្រោះថ្នាក់ពីអ្នកឈ្លានពាន ដើម្បីឲ្យវាផ្តល់នូវវិធានការសុវត្ថិភាពនានាដែលបានគ្រោងទុកសំរាប់ការគេចចេញចំពោះគ្រួសាររបស់លោកអ្នក ប្រសិនបើមានភ្លើងឆេះកើតឡើងនោះ ។**

### វិធានការសន្តិសុខនានាដែលអាចមានឥទ្ធិពលដល់ការគេចចេញពីភ្លើងឆេះរបស់លោកអ្នកគឺមាន ៖

- ☐ ការដាក់សោ ដែតឡក់ (dead lock) និង/ឬ សោជាច្រើនជាន់នៅនឹងទ្វារក្រៅ ។
- ☐ ការដាក់ចំរឹងដែកនិង រនុកដែកសន្តិសុខនៅនឹងបង្អួច ឬ សំណាញ់សន្តិសុខនៅនឹងទ្វារ ។
- ☐ ការដាក់សោ ឬ រនាំងបង្ហា (roller shutters) នៅនឹងបង្អួច ។

### វិធានការសុវត្ថិភាពនៃភ្លើងឆេះដែលគួរតែរាប់បញ្ចូលនៅក្នុងផ្ទះរបស់លោកអ្នក ៖

- ☐ ផ្ទះ ឬ ផ្ទះយូនិត(Unit) និមួយៗគួរតែមានគ្រឿងឲ្យសញ្ញាពេលមានផ្សែង (smoke alarms) គ្រប់គ្រាន់ដែលស្របតាមខ្នាតអូស្ត្រាលី (AS3786) ដាក់នៅក្នុងផ្ទះដែលត្រូវធ្វើតេស្តជារឿយៗ ។
- ☐ គួរតែមាន (smoke alarms) នៅគ្រប់ជាន់នៃផ្ទះរបស់លោកអ្នក ។
- ☐ សូមដឹងផ្លូវសុវត្ថិភាពពីរចេញពីបន្ទប់និមួយៗ-សូមចងចាំថា រាល់វិនាទីសំខាន់ណាស់ ។
- ☐ សូមគូរផែនការគេចចេញនៅលើក្រដាស់ហើយពិគ្រោះគ្នានិងហាត់តាមផែនការនោះជាមួយគ្រួសារលោកអ្នក ។
- ☐ សូមធ្វើឲ្យប្រាកដថាទ្វារនិងបង្អួចនិមួយៗឬទាំងអស់អាចបើកបានយ៉ាងរហ័ស ប្រសិនបើ និង ត្រូវការបើកវា ។
- ☐ សូមធ្វើឲ្យប្រាកដថាកូនសោទ្វារទាំងអស់អាចរកបានដោយងាយនៅពេលត្រូវការវា ។
- ☐ ពិការរាងកាយ ឬទន់ខ្សោយដោយសារមានអាយុច្រើនអាចប៉ះពាល់ខ្លាំងដល់លទ្ធភាពរបស់លោកអ្នកក្នុងការជៀសផុតពីគ្រោះថ្នាក់ ប្រសិនបើសំណាងអាក្រក់ត្រូវជាប់នៅក្នុងផ្ទះដែលមានភ្លើងឆេះ ។

### តើមានអ្វីខ្លះទៀតដែលលោកអ្នកត្រូវធ្វើឲ្យផ្ទះលោកអ្នកមានសុវត្ថិភាពនៃភ្លើងឆេះ?

- ☐ អ្នកដែលដេកលក់ស៊ប់ដូចជាកូនក្មេង ឬអ្នកដែលផឹកស្រាស្រវឹង ឬគ្រឿងញៀនប្រហែលជាមិនអាចភ្ញាក់បានដោយសារសម្លេងនៃគ្រឿងឲ្យសញ្ញាទេ ។ សូមឲ្យប្រាកដថាអ្វីដែលមិនបានគ្រោងទុកនោះត្រូវមាននៅក្នុងផែនការគេចចេញពីផ្ទះរបស់លោកអ្នក ។
- ☐ សូមមើលក្រដាស់ហេតុការណ៍ដ៏ទៃទៀតសំរាប់យកពត៌មានបន្ថែមស្តីពីសុវត្ថិភាពនៃភ្លើងឆេះ ។

**ចំពោះពត៌មានថែមទៀត សូមទាក់ទងស្ថានីយ៏រលត់ភ្លើង ឬមជ្ឈមណ្ឌលត្រួតត្រាភ្លើងតាមតំបន់លោកអ្នក ។**

**ឬ មើលវែបសៃ: www.fire.nsw.gov.au www.rfs.nsw.gov.au or www.esa.act.gov.au**

## ចំណុចសំខាន់ៗអំពីសុវត្ថិភាពនៃភ្លើងឆេះ

- សូមចងចាំថាផ្សែងពីភ្លើងនឹងធ្វើឲ្យលោកអ្នកច្របូកច្របល់ហើយលោកអ្នកក៏ពុំអាចមើលឃើញនៅក្នុងផ្សែងទេ ។
- ប្រសិនបើលោកអ្នកបានគេចចេញពីភ្លើងឆេះផ្ទះ, សូមចងចាំថាកាលបើលោកអ្នកចេញហើយ សូមនៅក្រៅហើយទូរស័ព្ទលេខ 000 ។
- សូមបង្ហាត់កូនលោកអ្នកឲ្យចេះផែនការគេចចេញពីភ្លើងឆេះ ហើយនិងហាត់មុននឹងហ្វឹកហ្វឺនការគេចចេញពីភ្លើងឆេះ ។
- ប្រសិនបើសមាជិកគ្រួសារម្នាក់មានបញ្ហាត្រចៀក ឬចលនា សូមធ្វើឲ្យប្រាកដថាលោកអ្នកគិតគេផង ហើយបើចាំបាច់, សូមចាត់ឲ្យអ្នកណាម្នាក់ជយយគេគេចចេញ ។
- សុវត្ថិភាពនៃភ្លើងឆេះផ្ទះជាការសំខាន់ណាស់ចំពោះគ្រួសារទាំងអស់ ហើយការត្រៀមលក្ខណៈជាមុនអាចការពារពីគ្រោះថ្នាក់បាន ។

**ក្នុងពេលអាសន្ន សូមទូរស័ព្ទលេខ 000**